# សេចក្តីថ្លែងការណ៍រួម
# ការគំរាមកំហែងទៅលើអ្នកវិភាគគឺជាការគំរាមកំហែងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១

យើងខ្ញុំជាអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ សហជីព និងសហគមន៍ ដែលមានឈ្មោះដូចខាងក្រោមសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») សូមមេត្តាបញ្ឈប់ការបំភិតបំភ័យលើអ្នកវិភាគបញ្ហាសង្គមនៅកម្ពុជា និងសំឡេងរិះគន់ផ្សេងទៀត ដោយគ្រាន់អ្នកទាំងនោះបញ្ចេញទស្សនៈនិងការយល់ឃើញសម្រាប់ផលប្រយោជន៍សាធារណៈនៅកម្ពុជា និងសូមមេត្តាគោរពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។

នៅក្នុងសុន្ទរកថាដែលបានធ្វើឡើងកាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រី លោកបានព្រមានអ្នកវិភាគបញ្ហាសង្គមនៅកម្ពុជា ចំពោះការអត្ថាធិប្បាយទៅលើគោលនយោបាយការបរទេសកម្ពុជា។ ជាក់ស្តែង ឈ្មោះរបស់លោកបណ្ឌិត មាស នី ជាអ្នកវិភាគមួយរូបដែលបានធ្វើអត្ថាធិប្បាយរិះគន់អំពីគោលនយោបាយការបរទេសរបស់កម្ពុជាជាមួយប្រទេសចិន ត្រូវបានលើកឡើង ហើយលោករងការព្រមានថា «កុំព្រហើនពេក»។ សម្តេចនាយករដ្ឋមន្ត្រីក៏បានលើកឡើងផងដែរ អំពីការចេញដីកាចាប់ខ្លួនអ្នកវិភាគមួយរូបផ្សេងទៀតដែលបានបង្ហោះលក្ខខណ្ឌប្រាំមួយចំណុចអំពីការបង្កើតរដ្ឋាភិបាលបង្រួបបង្រួមជាតិ នៅលើបណ្តាញសង្គមហ្វេសប៊ុករបស់ខ្លួន។ ក្រោយមក អ្នកវិភាគរូបនោះត្រូវបានបញ្ជាក់ថាជាលោកបណ្ឌិត សេង សារី ហើយលោករងការព្រមានថា ប្រសិនបើការបង្ហោះនោះមិនត្រូវបានដកចេញពីហ្វេសប៊ុកទេ នោះសកម្មភាពខាងលើរបស់លោកនឹងត្រូវបានគេចាត់ទុកថាជាបទល្មើសជាក់ស្តែង ហើយអាចនឹងត្រូវចាប់ខ្លួនពេលណាក៏បាន។ ក្រោយមក នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ សម្តេចនាយករដ្ឋមន្ត្រីក៏បានបង្ហោះសារនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនដោយបញ្ជាក់ថា ការបកស្រាយរបស់លោកបណ្ឌិត សេង សារី មានលក្ខណៈសមហេតុសមផល និងអាចទទួលយកបាន ព្រមទាំងអំពាវនាវឱ្យតុលាការពិចារណាបញ្ចប់នីតិវិធីច្បាប់ទៅលើលោកបណ្ឌិត សេង សារី ផងដែរ។

ការគំរាមកំហែងលើអ្នកវិភាគបញ្ហាសង្គម និងនយោបាយ ដោយគ្រាន់តែអ្នកទាំងនោះប្រើប្រាស់សេរីភាពខាងការបញ្ចេញមតិស្របច្បាប់ មិនគួរត្រូវបានធ្វើឡើងតាំងពីដំបូងមកម្ល៉េះ។ ការគំរាមកំហែងបែបនេះបង្កជាគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សេរីភាពខាងការបញ្ចេញមតិ ដែលត្រូវបានការពារដោយច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ សេរីភាពខាងការបញ្ចេញមតិគឺជាសេរីភាពមូលដ្ឋានរបស់ពលរដ្ឋគ្រប់រូប ដោយមិនគួរត្រូវបានការពារ និងគោរព តែនៅពេលដែលប្រើប្រាស់ដើម្បីសរសើររាជរដ្ឋាភិបាលនោះទេ ត្រូវតែត្រូវបានអាជ្ញាធរគោរព និងការពារគ្រប់ការបញ្ចេញមតិទាំងអស់។ អ្នកវិភាគបញ្ហាសង្គម និងនយោបាយគួរតែអាចអនុវត្តការងាររបស់ខ្លួនដោយស្របច្បាប់ និងផ្សព្វផ្សាយ

នូវអ្វីដែលពួកគេរកឃើញដោយគ្មានការគំរាមកំហែង ឬការព្រមានណាមួយ ទោះបីជាទស្សនៈទាំងនោះមិនពេញចិត្តចំពោះរដ្ឋាភិបាលក៏ដោយ។

យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមមេត្តាបញ្ឈប់ការបំភិតបំភ័យ និងដាក់ទោសដល់អ្នកដែលបានបញ្ចេញមតិបែបរិះគន់ ឬមតិផ្ទុយ ហើយសូម មេត្តាបង្ហាញពីភាពបើកចន្ទៈទូលាយក្នុងការស្តាប់ ហើយគោរពសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់ពលរដ្ឋខ្មែរគ្រប់រូប ជាពិសេសទោះបីជាទស្សនៈទាំងនោះមិនស្របតាមគំនិតរបស់អាជ្ញាធររដ្ឋក៏ដោយ៕

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍រួមនេះ មានរាយនាមដូចខាងក្រោម៖**

1 ក្រុមការងារដើម្បីដោះស្រាយទំនាស់
2 អង្គការអភិវឌ្ឍន៍សំលេងសហគមន៍
3 សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា
4 មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
5 មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
6 សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា
7 អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
8 សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា (អាដហុក)
9 សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ
10 វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា
11 សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)
12 អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ
13 បណ្តាញយុវជនកម្ពុជា
14 មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស (សង់ត្រាល់)
15 សម្ព័ន្ធសហគមន៍កសិករកម្ពុជា
16 គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
17 បណ្តាញកសាងសន្តិភាពសហគមន៍
18 អង្គការសមធម៌កម្ពុជា
19 សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ

20 សមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍

21 មូលនិធិ Manushya

22 គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា

23 អង្គការពន្លកខ្មែរ

24 អង្គការសមាគមជាងត្នោត

25 វិទ្យាស្ថានតស៊ូមតិ និង គោលនយោបាយ

26 បណ្តាញប្រជាធិបតេយ្យអាស៊ី

27 អង្គការតម្លាភាពកម្ពុជា

28 អង្គការអភិវឌ្ឍន៍ធនធានយុវជន (កអធយ)